Australian Electoral Commission

Khmer/ខ្មែរ

# សៀវភៅមគ្គុទ្ទេសក៍ផ្លូវការរបស់អ្នក

## ទៅកាន់ការបោះឆ្នោតសហព័ន្ធ ឆ្នាំ 2022

**ថ្ងៃសៅរ៍ ទី 21 ខែឧសភា ឆ្នាំ 2022**

**ការបោះឆ្នោតគឺជាកាតព្វកិច្ច**

សម្រាប់ពលរដ្ឋអូស្ត្រាលីដែលមានអាយុ 18 ឆ្នាំ និងអាយុលើសនេះ



## ការបោះឆ្នោតរបស់អ្នក នឹងជួយរៀបចំអនាគតប្រទេសអូស្ត្រាលី

# សារចេញពី
## ស្នងការរៀបចំការបោះឆ្នោត

AEC បានបង្កើតសៀវភៅមគ្គុទ្ទេសក៍នេះ ដើម្បីជួយអ្នករៀបចំផែនការសម្រាប់ការបោះឆ្នោតរបស់អ្នក នៅក្នុងការបោះឆ្នោតសហព័ន្ធនេះ។ សៀវភៅមគ្គុទ្ទេសក៍រៀបរាប់យ៉ាងលម្អិត អំពីរបៀបបោះឆ្នោតឱ្យបានត្រឹមត្រូវ អ្វីដែលកើតឡើងនៅកន្លែងបោះឆ្នោត សំណួរដែលគេតែងសួរជាញឹកញាប់ និងគន្លឹះសំខាន់ៗអំពីរបៀបពិនិត្យមើលប្រភពព័ត៌មាន។

យើងនឹងមានកន្លែងបោះឆ្នោតបើកនៅទូទាំងប្រទេសនៅថ្ងៃបោះឆ្នោត ក៏ដូចជាជម្រើសបោះឆ្នោតផ្សេងទៀត ដើម្បីគាំទ្រសហគមន៍ឱ្យបញ្ចេញមតិរបស់ពួកគេ។

**អ្នកអាចមានទំនុកចិត្តថា៖**

- យើងកំពុងចាត់ចែងដំណើរការបោះឆ្នោតដោយ**សុចរិតភាព** ធានាការបោះឆ្នោតរបស់អ្នកនៅគ្រប់ជំហាននៃដំណើរការ – ចាប់ពីការបោះពុម្ព រហូតដល់ការរាប់សន្លឹកឆ្នោតរបស់អ្នក។
- **សុខភាព និងសុវត្ថិភាព**របស់អ្នក និងរបស់បុគ្គលិកចាត់ចែងការបោះឆ្នោតរបស់យើង គឺជាអាទិភាពមួយ ហើយវិធានការសុវត្ថិភាព COVID-19 ជាច្រើននឹងត្រូវបានដាក់ឱ្យដំណើរការ។

ការផ្លាស់ប្តូរគំនិតដ៏រឹងមាំគឺជាផ្នែកនៃការឃោសនាបោះឆ្នោត ហើយខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យពិចារណាដោយប្រុងប្រយ័ត្ននូវព័ត៌មានទាំងអស់ដែលអ្នកទទួលបាន ប៉ុន្តែជាពិសេសអ្វីៗដែលចោទសួរ អំពីដំណើរការបោះឆ្នោតដែលបានបង្កើតឡើងយ៉ាងល្អរបស់យើង។ **សួរខ្លួនអ្នកថាតើវាមកពីប្រភពដែលទទួលស្គាល់ និងអាចទុកចិត្តបានដែរឬទេ។** ប្រសិនបើចម្លើយថាទេ សំណូមពររបស់ខ្ញុំគឺត្រូវប្រុងប្រយ័ត្ន។

សូមចូលទៅកាន់គេហទំព័រ **aec.gov.au** សម្រាប់ព័ត៌មានបន្ថែម អំពីរបៀបដែលអ្នកអាចបញ្ចេញមតិរបស់អ្នកនៅក្នុងការបោះឆ្នោតនេះ។

**Tom Rogers**
ស្នងការរៀបចំការបោះឆ្នោត

**ច្រើនជាង** 96%
នៅលើបញ្ជីបោះឆ្នោត

7,000+
កន្លែងបោះឆ្នោត

500+
មណ្ឌលបោះឆ្នោតមុនពេលកំណត់

100,000+
បុគ្គលិករៀបចំការបោះឆ្នោតបណ្តោះអាសន្ន

# ឈប់ ហើយពិចារណា
## ពិនិត្យមើលប្រភពនៃការបោះឆ្នោតសហព័ន្ធនេះ

ក្នុងអំឡុងពេលបោះឆ្នោត ព័ត៌មានមួយចំនួនធំត្រូវបានចែកចាយ មានគោលបំណងដាក់ឥទ្ធិពលលើការបោះឆ្នោតរបស់អ្នក។

នេះគឺជាផ្នែកសំខាន់មួយនៃដំណើរការប្រជាធិបតេយ្យ។ វាផ្តល់ឱ្យបេក្ខជន គណបក្សនយោបាយនានា និងអ្នកផ្សេងទៀតនូវមធ្យោបាយ ដើម្បីផ្សព្វផ្សាយគោលនយោបាយ និងជំនឿរបស់ពួកគេជាមួយអ្នកបោះឆ្នោត។

ទោះជាយ៉ាងណាក្តី ព័ត៌មានខ្លះអាចមិនពិត ឬបំភាន់ដោយចេតនា។

វាសំខាន់ណាស់ដែលអ្នកត្រូវពិចារណាដោយប្រុងប្រយ័ត្ន នូវអ្វីៗដែលអ្នកឃើញ ស្តាប់ឮ ឬអានអំពីការបោះឆ្នោតសហព័ន្ធ។

សូមចំណាយពេលដើម្បីពិចារណាថាតើព័ត៌មាននោះ៖

- មកពីប្រភពដែលអាចទុកចិត្តបាន ឬអាចទទួលស្គាល់ឬអត់
- បច្ចុប្បន្ន
- មានសុវត្ថិភាព (មិនមែនជាការបោកប្រាស់)។

នេះមានសារៈសំខាន់ ជាពិសេសពេលនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម និងអនឡាញ។

សូមចូលទៅកាន់គេហទំព័រ **aec.gov.au/stopandconsider** សម្រាប់ព័ត៌មានបន្ថែម និងវីដេអូខ្លីៗដែលមានគន្លឹះសំខាន់ៗដ៏មានប្រយោជន៍។



# ថ្ងៃបោះឆ្នោតគឺថ្ងៃសៅរ៍ ទី 21 ខែឧសភា ឆ្នាំ 2022

## កន្លែងបោះឆ្នោតបើកនៅម៉ោង 8 ព្រឹក ហើយបិទនៅម៉ោង 6 ល្ងាចគត់។

ការបោះឆ្នោតសហព័ន្ធត្រូវបានរៀបចំឡើង ដើម្បីឱ្យប្រជាជនអូស្ត្រាលីអាចជ្រើសរើសសមាជិកសភាជាតំណាងទស្សនៈ និងផលប្រយោជន៍របស់ពួកគេនៅក្នុងសភាតំណាងរាស្ត្រ និងព្រឹទ្ធសភា។

### តើអ្នកណាខ្លះត្រូវតែបោះឆ្នោត?

ពលរដ្ឋអូស្ត្រាលីទាំងអស់ដែលមានអាយុ 18 ឆ្នាំ និងអាយុលើសនេះ ត្រូវបានតម្រូវឱ្យចុះឈ្មោះ និងបោះឆ្នោតនៅក្នុងការបោះឆ្នោតសហព័ន្ធ។

### តើខ្ញុំអាចបោះឆ្នោតនៅឯណា?

អ្នកអាចបោះឆ្នោតនៅកន្លែងបោះឆ្នោតណាមួយក្នុងរដ្ឋ ឬដែនដីរបស់អ្នកនៅថ្ងៃបោះឆ្នោត។ កន្លែងបោះឆ្នោតបើកពីម៉ោង 8 ព្រឹក ទៅម៉ោង 6 ល្ងាច។

កន្លែងបោះឆ្នោតជាធម្មតាមានទីតាំងនៅសាលារៀន ព្រះវិហារ និងសាលសហគមន៍ ឬអគារសាធារណៈ។ ដើម្បីស្វែងរកកន្លែងបោះឆ្នោតដែលនៅជិតអ្នកបំផុត សូមចូលទៅកាន់គេហទំព័រ **aec.gov.au/where**

ប្រសិនបើអ្នកមានការលំបាកផ្នែកចល័តភាព ឬពិការភាព ឬថែទាំនរណាម្នាក់ដែលមានពិការភាព អ្នកអាចពិនិត្យមើលព័ត៌មានលម្អិតអំពីច្រកផ្លូវចេញចូលនៃកន្លែងបោះឆ្នោតនៅតាមគេហទំព័រ **aec.gov.au/where**

ចំពោះជម្រើសបោះឆ្នោតសម្រាប់មនុស្សខ្វាក់ ឬអន់ខ្សោយភ្នែក សូមចូលមើលគេហទំព័រ **aec.gov.au/assistance** ឬទូរសព្ទលេខ **13 23 26**។

### ចុះបើខ្ញុំនៅរដ្ឋ ឬដែនដីផ្សេងទៀត?

ប្រសិនបើអ្នកនឹងស្ថិតនៅរដ្ឋផ្សេងទៀតនៅថ្ងៃបោះឆ្នោត អ្នកអាចបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតអន្តររដ្ឋដែលបានកំណត់ ឬពិចារណាលើជម្រើសបោះឆ្នោតមុនពេលកំណត់ដែលអាចរកបានខាងក្រោមនេះ។

### ចុះបើខ្ញុំមិនអាចទៅកន្លែងបោះឆ្នោតនៅថ្ងៃបោះឆ្នោតបានទេ?

ប្រសិនបើអ្នកមិនអាចទៅកន្លែងបោះឆ្នោតនៅថ្ងៃបោះឆ្នោតបានទេ អ្នកប្រហែលជាអាចមានសិទ្ធិបោះឆ្នោតមុនពេលកំណត់ដោយផ្ទាល់ខ្លួន ឬតាមប្រៃសណីយ៍។

### របៀបបោះឆ្នោតមុនពេលកំណត់ដោយផ្ទាល់ខ្លួន

ប្រសិនបើអ្នកមានសិទ្ធិ អ្នកអាចបោះឆ្នោតមុនថ្ងៃបោះឆ្នោត។ មណ្ឌលបោះឆ្នោតមុនពេលកំណត់បើកពី**ថ្ងៃចន្ទ ទី 9 ខែឧសភា ឆ្នាំ 2022**។ កាលបរិច្ឆេទ និងម៉ោងបើកដំណើរការខុសៗគ្នា ដូច្នេះសូមចូលមើលគេហទំព័រ **aec.gov.au/where** ដើម្បីពិនិត្យមើលព័ត៌មានលម្អិតសម្រាប់មណ្ឌលនីមួយៗ។

សម្រាប់ព័ត៌មានបន្ថែមអំពីការបោះឆ្នោតមុនពេលកំណត់ និងដើម្បីពិនិត្យមើលថាតើអ្នកមានសិទ្ធិដែរឬទេ សូមចូលមើលគេហទំព័រ **aec.gov.au/early** ឬទូរសព្ទទៅលេខ **13 23 26**។

### របៀបបោះឆ្នោតមុនពេលកំណត់តាមប្រៃសណីយ៍

ការបោះឆ្នោតតាមប្រៃសណីយ៍មានសម្រាប់អ្នកបោះឆ្នោតដែលមានសិទ្ធិ។ ពិនិត្យមើលភាពមានសិទ្ធិរបស់អ្នក ហើយដាក់ពាក្យតាមអនឡាញ នៅតាមគេហទំព័រ **aec.gov.au/pva**

បំពេញពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍របស់អ្នក ដើម្បីផ្ញើវាឱ្យបានដល់ AEC **មិនលើសពីម៉ោង 6 ល្ងាច ថ្ងៃពុធ ទី 18 ខែឧសភា ឆ្នាំ 2022**។

សូមទូរសព្ទទៅលេខ **13 23 26** ប្រសិនបើអ្នកមិនមានលទ្ធភាពចូលដំណើរការតាមអនឡាញ ហើយចង់ដាក់ពាក្យបោះឆ្នោតតាមប្រៃសណីយ៍។

### តើខ្ញុំស្ថិតនៅមណ្ឌលបោះឆ្នោតមួយណា?

អ្នកអាចពិនិត្យមើលថាតើមណ្ឌលមួយណាដែលអ្នករស់នៅ នៅតាមគេហទំព័រ **aec.gov.au/electorate**

ប្រសិនបើអ្នករស់នៅក្នុង**រដ្ឋអូស្ត្រាលីខាងលិច** ឬ**រដ្ឋវិចថូរៀ** ឈ្មោះ ឬព្រំដែននៃមណ្ឌលបោះឆ្នោតរបស់អ្នកអាចត្រូវបានផ្លាស់ប្តូរចាប់តាំងពីការបោះឆ្នោតសហព័ន្ធចុងក្រោយ ដែលជាលទ្ធផលនៃការបែងចែកព្រំដែនឡើងវិញ។ អ្នកប្រហែលជាត្រូវបោះឆ្នោតនៅតាមមណ្ឌលមួយផ្សេងទៀត ឬក៏កន្លែងបោះឆ្នោតធម្មតារបស់អ្នកអាចស្ថិតនៅមណ្ឌលមួយផ្សេងទៀត។

### នរណាដែលអ្នកបោះឆ្នោតឱ្យនោះ គឺជាការសម្រេចចិត្តរបស់អ្នកទេ

នៅក្រៅកន្លែងបោះឆ្នោត អ្នកតំណាងបេក្ខជនឈរឈ្មោះបោះឆ្នោត ប្រហែលជាហុចប័ណ្ណរបៀបបោះឆ្នោតឱ្យអ្នក ដែលស្នើសុំឱ្យអ្នកបោះឆ្នោត ក្នុងលំនាំជាក់លាក់មួយ។ អ្នកមិនចាំបាច់ត្រូវតែទទួលយក ឬធ្វើតាមប័ណ្ណរបៀបបោះឆ្នោតទាំងនោះឡើយ។

តើមានសំណួរមួយទៀតឬ?
ចូលទៅកាន់គេហទំព័រ
**aec.gov.au/faqs**



# របៀបឱ្យសន្លឹកឆ្នោតរបស់អ្នកយកជាផ្លូវការបាន

នៅថ្ងៃបោះឆ្នោត អ្នកនឹងបានទទួលសន្លឹកឆ្នោតពីរសន្លឹក៖ សន្លឹកឆ្នោតពណ៌បៃតងតូច គឺសម្រាប់សភាតំណាងរាស្ត្រ ហើយសន្លឹកឆ្នោតពណ៌សធំ គឺសម្រាប់ព្រឹទ្ធសភា។ **អ្នកត្រូវតែបំពេញសន្លឹកឆ្នោតទាំងពីរ។** នៅលើសន្លឹកឆ្នោតពណ៌បៃតង អ្នកបោះឆ្នោតជ្រើសរើសអ្នកតំណាងតំបន់មូលដ្ឋាន ឬមណ្ឌលបោះឆ្នោតរបស់អ្នកនៅក្នុងសភាតំណាងរាស្ត្រ។ នៅលើសន្លឹកឆ្នោតពណ៌ស អ្នកបោះឆ្នោតជ្រើសរើសអ្នកតំណាងរដ្ឋ ឬដែនដីរបស់អ្នកនៅក្នុងព្រឹទ្ធសភា។

## សភាតំណាងរាស្ត្រ

នៅលើសន្លឹកឆ្នោតពណ៌បៃតង សូម**ដាក់លេខប្រអប់នីមួយៗ** ទៅតាមលំដាប់នៃជម្រើសរបស់អ្នក។




សន្លឹកឆ្នោតគំរូ

**សូមកុំខ្វល់ព្រួយអ្វីឡើយ ប្រសិនបើអ្នកបំពេញខុស។**
អ្នកអាចស្នើសុំសន្លឹកឆ្នោតមួយផ្សេងទៀត ហើយចាប់ផ្តើមបំពេញម្តងទៀត។

## ព្រឹទ្ធសភា

នៅលើសន្លឹកឆ្នោតពណ៌ស អ្នកមានជម្រើសពីរដើម្បីបោះឆ្នោត៖

**មួយណាក៏បាន**

### នៅលើខ្សែបន្ទាត់

ប្រសិនបើអ្នកជ្រើសរើសបោះឆ្នោតនៅលើខ្សែបន្ទាត់ អ្នកចាំបាច់ត្រូវ**ដាក់លេខឱ្យបានយ៉ាងហោចណាស់ 6 ប្រអប់**។

ដាក់លេខ '1' នៅក្នុងប្រអប់សម្រាប់គណៈបក្ស ឬក្រុមដែលជាជម្រើសទីមួយរបស់អ្នក ហើយដាក់លេខ '2' សម្រាប់ជម្រើសទីពីររបស់អ្នក ហើយជាបន្តបន្ទាប់ រហូតទាល់តែអ្នកបានដាក់លេខយ៉ាងហោចណាស់ 6 ប្រអប់។ អ្នកអាចបន្តដាក់លេខទៅតាមលំដាប់នៃជម្រើសរបស់អ្នក នៅក្នុងប្រអប់យ៉ាងច្រើននៅលើខ្សែបន្ទាត់ តាមដែលអ្នកចូលចិត្ត។




សន្លឹកឆ្នោតគំរូ

**ឬ**

### នៅក្រោមខ្សែបន្ទាត់

ប្រសិនបើអ្នកជ្រើសរើសបោះឆ្នោតនៅក្រោមខ្សែបន្ទាត់ អ្នកចាំបាច់ត្រូវ**ដាក់លេខឱ្យបានយ៉ាងហោចណាស់ 12 ប្រអប់** ចាប់ពី 1 ទៅ 12 សម្រាប់បេក្ខជនម្នាក់ៗ ទៅតាមលំដាប់នៃជម្រើសរបស់អ្នក។ អ្នកអាចបន្តដាក់លេខទៅតាមលំដាប់នៃជម្រើសរបស់អ្នក នៅក្នុងប្រអប់យ៉ាងច្រើននៅក្រោមខ្សែបន្ទាត់ តាមដែលអ្នកចូលចិត្ត។




សន្លឹកឆ្នោតគំរូ

# អ្វីដែលអ្នកអាចធ្វើបាន ដើម្បីរៀបចំផែនការ មុនអ្នកបោះឆ្នោត

BE COVIDSAFE

អ្នកអាចចាត់វិធានការដើម្បីរក្សាសុវត្ថិភាពខ្លួនអ្នក និងអ្នកដទៃនៅពេលបោះឆ្នោត។

- **តើមានរោគសញ្ញា COVID-19 ទេ? សូមអរគុណចំពោះការមិនអញ្ជើញមកកន្លែងបោះឆ្នោត។**
- ប្រសិនបើមិនស្រួលខ្លួន អ្នកប្រហែលជាមានសិទ្ធិដាក់ពាក្យបោះឆ្នោតតាមប្រៃសណីយ៍។ អ្នកអាចដាក់ពាក្យតាមអនឡាញ នៅតាមគេហទំព័រ **aec.gov.au/pva** រហូតដល់ **ថ្ងៃទី 6 ល្ងាច ថ្ងៃពុធ ទី 18 ខែឧសភា ឆ្នាំ 2022។**
- ធ្វើការស្រាវជ្រាវរបស់អ្នកលើបេក្ខជន និងចំណង់ចំណូលចិត្ត មុនពេលចូលរួមការបោះឆ្នោត។ បញ្ជីរាយនាមបេក្ខជនមាននៅគេហទំព័រ **aec.gov.au/election/candidates.htm**
- កន្លែងណាដែលអាចធ្វើទៅបាន មានតែអ្នកបោះឆ្នោតពិតប្រាកដប៉ុណ្ណោះ ដែលគួរតែទៅកន្លែងបោះឆ្នោត។
- ជៀសវាងការធ្វើទំនាក់ទំនងជាមួយមនុស្សក្នុងសង្គម និងចំណាយពេលបន្ថែមទៀតនៅឬជុំវិញកន្លែងបោះឆ្នោត។

ចូលទៅកាន់គេហទំព័រ **aec.gov.au/covid-safety** ដើម្បីទទួលបានព័ត៌មានបច្ចុប្បន្នភាព និងដំបូន្មានថ្មីៗ

# តើមានអ្វីកើតឡើងនៅកន្លែងបោះឆ្នោត?

## ជំហានបោះឆ្នោត

1. មន្ត្រីជំនួយការបោះឆ្នោតនឹងសួរឈ្មោះពេញ និងអាសយដ្ឋានរបស់អ្នក ហើយថាតើអ្នកបានបោះឆ្នោតហើយឬនៅ នៅក្នុងការបោះឆ្នោតនេះ។ គេនឹងគូសឈ្មោះរបស់អ្នកចេញពីបញ្ជីបោះឆ្នោត។
2. អ្នកនឹងទទួលបានសន្លឹកឆ្នោតរបស់អ្នក។
3. នៅបន្ទប់បោះឆ្នោត សូមអានសេចក្តីណែនាំដែលមានចុះនៅលើសន្លឹកឆ្នោតរបស់អ្នកដោយប្រុងប្រយ័ត្ន ឬស្នើសុំជំនួយពីមន្ត្រីជំនួយការបោះឆ្នោត។
4. បំពេញសន្លឹកឆ្នោតរបស់អ្នក។
5. បត់សន្លឹកឆ្នោតរបស់អ្នក ហើយដាក់វាទៅក្នុងប្រអប់សន្លឹកឆ្នោត។

## វិធានការសុវត្ថិភាព COVID-19 នៅនឹងកន្លែង

- អាចមានការកំណត់ចំពោះចំនួនអ្នកបោះឆ្នោតនៅខាងក្នុងកន្លែងបោះឆ្នោតនៅពេលណាមួយ។ អ្នកអាចត្រូវបានស្នើសុំឱ្យតម្រង់ជួរនៅខាងក្រៅ។
- រក្សាគម្លាត 1.5 ម៉ែត្រពីអ្នកឯទៀតនៅខាងក្រៅ និងខាងក្នុង ហើយនៅកន្លែងបោះឆ្នោត សូមធ្វើតាមសញ្ញាសម្គាល់នៅលើកម្រាលជាការណែនាំ។
- ចុះឈ្មោះចូលដោយប្រើកូដ QR ឬដោយដៃ។
- អនុលោមតាមតម្រូវការពាក់ម៉ាស់នៅក្នុងតំបន់របស់អ្នក។
- ប្រើទឹកថ្នាំអនាម័យសម្អាតដៃដែលបានផ្តល់។
- បន្ទប់បោះឆ្នោត និងខ្មៅដៃនឹងត្រូវបានសម្អាតជាប្រចាំ។ សូមយកប៊ិច ឬខ្មៅដៃផ្ទាល់ខ្លួនរបស់អ្នកមកជាមួយ ប្រសិនបើអ្នកចង់ ប៉ុន្តែសូមកុំទុកវាចោលនៅទីនោះ។



**សូមស្នាក់នៅផ្ទះ ប្រសិនបើអ្នកមានរោគសញ្ញា COVID-19 ណាមួយ**



**គ្របការក្អក និងកណ្តាស់របស់អ្នក**



**ពិនិត្យមើលតម្រូវការពាក់ម៉ាស់ក្នុងតំបន់**




**ឈរគម្លាត 1.5 ម៉ែត្រ**



**ប្រើទឹកថ្នាំអនាម័យសម្អាតដៃដែលបានផ្តល់**

វាជារឿងសំខាន់ក្នុងការធ្វើតាមគោលការណ៍ណែនាំអំពីសុខភាពស្តីពី COVID-19 របស់រដ្ឋាភិបាលរដ្ឋ និងដែនដីរបស់អ្នក។ តំណភ្ជាប់ទៅកាន់គោលការណ៍ណែនាំទាំងនេះ មាននៅលើគេហទំព័រ **aec.gov.au/covid-safety**

ព័ត៌មាននៅក្នុងការណែនាំនេះ ឆ្លុះបញ្ចាំងពីកាលៈទេសៈនានានៅពេលបោះពុម្ព។ AEC នឹងបន្តអនុវត្តតាមដំបូន្មានអាជ្ញាធរសុខាភិបាលសហព័ន្ធ និងរដ្ឋ ហើយវិធានការដែលបានធ្វើបច្ចុប្បន្នភាពណាមួយ នឹងមាននៅលើគេហទំព័ររបស់យើង។

# **សៀវភៅមគ្គុទ្ទេសក៍ផ្លូវការរបស់អ្នក** ទៅកាន់ការបោះឆ្នោតសហព័ន្ធ ឆ្នាំ 2022

## ថ្ងៃសៅរ៍ ទី 21 ខែឧសភា ឆ្នាំ 2022

# **កំណែជំនួសផ្សេងទៀត**នៃសៀវភៅមគ្គុទ្ទេសក៍នេះ

### ព័ត៌មានក្នុងទម្រង់ដែលអាចចូលប្រើប្រាស់បាន

អ្នកអាចទាញយកទម្រង់ផ្សេងៗនៃសេចក្ដីណែនាំនេះ ដូចជាសម្លេង និងការបោះពុម្ពជាអក្សរធំ នៅតាមគេហទំព័រ **aec.gov.au/assistance**

អក្សរសម្រាប់មនុស្សខ្វាក់ក៏មានផ្ដល់ជូនដែរតាមការស្នើសុំ ដោយហៅទូរសព្ទទៅលេខ **13 23 26**។

ប្រសិនបើអ្នកជាមនុស្សថ្លង់ ឬមានពិការភាពក្នុងការស្ដាប់ ឬនិយាយ សូមទាក់ទងមកយើងតាមរយៈ សេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ (NRS)៖

- អ្នកប្រើប្រាស់ TTY ទូរសព្ទលេខ **13 36 77** ហើយសម្រង់លេខ **13 23 26**។
- អ្នកប្រើប្រាស់សេវាកម្មនិយាយ និងស្ដាប់ (Speak and Listen) សូមទូរសព្ទលេខ **1300 555 727** ហើយសម្រង់លេខ **13 23 26**។
- អ្នកប្រើប្រាស់សេវាកម្មបន្តតាមអ៊ីនធឺណិត សូមតភ្ជាប់ទៅ NRS បន្ទាប់មកស្នើសុំលេខ **13 23 26**។
- សេវាកម្មបកប្រែផ្ទាល់មាត់ Auslan ក៏នឹងអាចរកបានដែរ។ ចូលមើលគេហទំព័រ AEC សម្រាប់ព័ត៌មានបន្ថែម។

### ព័ត៌មានជាភាសាផ្សេងៗ

**ការបកប្រែនៃសេចក្ដីណែនាំនេះជា 33 ភាសា អាចទាញយកបានពីគេហទំព័រ aec.gov.au/translated**

សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទក៏អាចរកបានផងដែរ។ សម្រាប់ព័ត៌មានអំពីការបោះឆ្នោត និងការបោះឆ្នោតជាភាសាខ្មែរ សូមហៅទូរសព្ទលេខ **1300 720 134**។




ការបោះឆ្នោតគឺជាកាតព្វកិច្ចសម្រាប់ពលរដ្ឋអូស្ត្រាលីអាយុ 18 ឆ្នាំ និងអាយុលើសនេះ។ ប្រសិនបើអ្នកមិនបោះឆ្នោតទេ អ្នកអាចត្រូវបានកាត់ទោស។ ប្រសិនបើអ្នកបោះឆ្នោតច្រើនជាងមួយដង នេះគឺជាបទល្មើសព្រហ្មទណ្ឌ។

AEC 21-1558

**aec.gov.au** 13 23 26

AEC Australian Electoral Commission

ផ្ដល់សិទ្ធិអនុញ្ញាតដោយស្នងការរៀបចំការបោះឆ្នោត 10 Mort Street, Canberra.
Authorised by the Electoral Commissioner, 10 Mort Street, Canberra.